**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីជូនដំណឹង

## ស្តីអំពី

## ការរៀបចំសន្និសីទសារព័ត៌មានស្តីពី «កម្មវិធីស្វ័យសិក្សា MoEYS E-Learning៖ ៥ខែបន្ទាប់ពីការដាក់ឲ្យប្រើប្រាស់ជាសាធារណៈ»

*ថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*
*ត្រូវនឹង ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១*

ក្រសួងអប់រំ យុវជន និងកីឡា និងសហភាពសហព័ន្ធយុវជនកម្ពុជា សូមជម្រាបជូន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចំណោះទូទៅគ្រប់កម្រិត អ្នកសារព័ត៌មាន និងសាធារណជន ជ្រាបអំពីការរៀបចំសន្និសីទសារព័ត៌មានក្នុងគោលបំណងធ្វើវឌ្ឍនភាពនៃកម្មវិធីស្វ័យសិក្សា MoEYS E-Learning ក្នុងរយៈពេល៥ខែបន្ទាប់ពីការដាក់ឲ្យប្រើប្រាស់ជាសាធារណៈ។ សន្និសីទសារព័ត៌មាននេះនឹងប្រព្រឹត្តទៅដូចមានរៀបរាប់ខាងក្រោម៖

**កាលបរិច្ឆេទ៖** ថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ត្រូវនឹង **ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៨ និង៣០នាទី ព្រឹក**

**ទីតាំង/ទម្រង់៖** ក្នុងបរិវេណ វិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ និងមានការផ្សាយផ្ទាល់លើគេហទំព័រហ្វេសប៊ុកផ្លូវការរបស់ ក្រសួងអប់រំ យុវជន និងកីឡា និងគេហទំព័រហ្វេសប៊ុកផ្លូវការរបស់ សហភាពសហព័ន្ធយុវជនកម្ពុជា (បញ្ជាក់៖ វត្តមានចូលរួមនៅទីតាំងគឺសម្រាប់តែអ្នកសារព័ត៌មាន និងភ្ញៀវកិត្តិយសដែលត្រូវបានអញ្ជើញតែប៉ុណ្ណោះ។)

**គណៈអធិបតី៖**
- **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានគណៈកម្មការអប់រំ យុវជន កីឡា កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា
- ឯកឧត្តម លោកជំទាវ អនុប្រធាន និងសមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាល សហភាពសហព័ន្ធយុវជនកម្ពុជា
- លោក លោកស្រី តំណាងក្រុមការងារបច្ចេកទេសតម្លើងApp

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អ្នកសារព័ត៌មាន និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន ក៏ដូចជាដើម្បីចូលរួមទស្សនាតាមការផ្សាយផ្ទាល់ដូចបានបញ្ជាក់ខាងលើ។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងកញ្ញា យ៉ាម៉ា សុជាតា តាមរយៈលេខទូរស័ព្ទ ០៦៩ ៤៤៤០៤៧ ឬលោក អ៊ឹង វិរៈ តាមរយៈលេខទូរស័ព្ទ ០៩២ ៩៩៩៥០៤។

សូមអរគុណ!